**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

សំណុំរឿងលេខ : ០០២/១៩-០៩-២០០៧-អវតក/អជតក
ដាក់ទៅ : អង្គជំនុំជម្រះតុលាការកំពូល
ថ្ងៃដាក់ : ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៤
ភាគីអ្នកដាក់ : សហព្រះរាជអាជ្ញា
ភាសាដើម : **អង់គ្លេស**

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 04-Dec-2014, 14:49
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើបន្ទាន់របស់ នួន ជា និង ខៀវ សំផន សុំពន្យារពេលដាក់ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសាលក្រមសំណុំរឿង០០២/០១**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រ៊ឹម, ប្រធាន
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C. N. JAYASINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele NUMBA

**ចម្លងជូន:**
**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Marie GUIRAUD

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោក Anta GUISSÉ
លោក Arthur VERCKEN

# I. ចម្លើយតបរួម

១. សហព្រះរាជអាជ្ញាបានទទួលសំណើរបស់ នួន ជា និង ខៀវ សំផន ដែលស្នើសុំពន្យារពេលដាក់ចម្លើយតបទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសាលក្រមសំណុំរឿង០០២/០១។ ខៀវ សំផន ស្នើសុំពេលសាមសិបថ្ងៃ ចាប់ពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ឬចាប់ពីថ្ងៃដែលគេអាចបាននូវច្បាប់បកប្រែជាភាសាបារាំង នៃបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ឬក៏មួយណាដែលចុងក្រោយគេ[1]។ នួន ជា ស្នើសុំពន្យារពេលសាមសិបថ្ងៃ ដោយគិតចាប់ពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ តទៅ[2]។

២. ចម្លើយតបទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញានេះ នឹងត្រូវផុតកំណត់នៅត្រឹមថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤។ សហព្រះរាជអាជ្ញាជឿថា ការពន្យារពេលណាមួយនឹងត្រូវបានអនុញ្ញាត ហើយនៅក្នុងកាលៈទេសៈនាពេលនេះ ការពន្យារពេល៥១ថ្ងៃ គិតចាប់ពីថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥ គឺជាការសមស្រប។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាមិនជំទាស់នឹងសំណើសុំពេល៣០ថ្ងៃដោយ នួន ជា គិតចាប់ពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ដើម្បីដាក់ចម្លើយតបរបស់គាត់ទេ។

៣. ប៉ុន្តែ មេធាវីការពារក្តី ខៀវ សំផន រហូតមកដល់ពេលនេះនៅតែជំនះនឹងការបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការចូលរួមក្នុងដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង០០២/០២ ដោយសន្មតថា ពួកគេគឺខុសពីភាគីដទៃ មិនអាចធ្វើការងារលើបណ្ដឹងសាទុក្ខផង និងសវនាការក្នុងពេលតែមួយផងបានទេ[3]។ សំណើសុំពន្យារពេលរបស់ពួកគាត់មិនបានបង្ហាញថា តើពួកគាត់នឹងបោះបង់ចោលយុទ្ធសាស្ត្រនេះដែរឬអត់នោះទេ បើអញ្ចឹង ថាតើការពន្យារពេលដែលនឹងធ្វើឡើងដោយអង្គជំនុំជម្រះតុលាការកំពូល រឹតតែធ្វើឱ្យមានផ្លាស់ប្ដូរកាន់តែអាក្រក់ទៅចំពោះសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលថា សវនាការជំនុំជម្រះក្ដីនៃសំណុំរឿង០០២/០២ នឹងចាប់ផ្ដើម "ឆាប់ៗតាមដែលអាចធ្វើទៅបាន"[4] នោះ។

---

[1] **F12** សំណើបន្ទាន់របស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំពន្យារពេលឆ្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, ១ ធ្នូ ២០១៤, កថាខណ្ឌទី៧។

[2] **F14** សំណើបន្ទាន់របស់ នួន ជា សុំពេលវេលាបន្ថែមដើម្បីឆ្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា*[sic]* ប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១, ២ ធ្នូ ២០១៤, កថាខណ្ឌទី៤។

[3] *សូមអាន* **E320/2** សេចក្ដីសម្រេចស្ដីពីការតែងតាំងមេធាវីដែលចាត់តាំងដោយតុលាការសម្រាប់ ខៀវ សំផន, ២១ វិច្ឆិកា ២០១៤។ **E1/246.1** ប្រតិចារឹកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង០០២/០២, ២៤ វិច្ឆិកា ២០១៤។

[4] **E284/4/8** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២, ២៥ វិច្ឆិកា ២០១៣, កថាខណ្ឌទី៧៦។

៤. សវនាការលើសំណុំរឿង០០២/០២ ត្រូវបានកំណត់ពេលចាប់ផ្តើមឡើងវិញ នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥[5]។ ដោយសារតែការប្រព្រឹត្តពីមុនៗ របស់ ខៀវ សំផន និងក្រុមមេធាវីការពារក្តីរបស់គាត់ សហព្រះរាជអាជ្ញា សូមស្នើថា មុននឹងអនុញ្ញាតពន្យារពេលឲ្យ ខៀវ សំផន សូមឲ្យអង្គជំនុំជម្រះនេះ ទទួលបាននូវការធានាពីក្រុមមេធាវីការពារក្តីរបស់គាត់ជាមុនសិន ថា ពួកគាត់នឹងមិនធ្វើការបង្អាក់បន្ថែមទៀត ដល់កិច្ចដំណើរការនីតិវិធីលើសំណុំរឿង០០២/០២ នេះទេ ដែលឈរលើមូលដ្ឋានថា ពួកគាត់នៅជាប់រវល់នៅក្នុងនីតិវិធីបណ្តឹងសាទុក្ខ។

៥. អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញា៖

ក. **សូមជម្រាបជូនដំណឹងដល់** អង្គជំនុំជម្រះតុលាការកំពូលថា សហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងការអនុញ្ញាតឲ្យជនជាប់ចោទម្នាក់ៗ ទទួលបាននូវពេលវេលាបន្ថែមចំនួន ៥១ (ហាសិបមួយ)ថ្ងៃ ដើម្បីដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា នោះទេ, ហើយនិង

ខ. **សូមស្នើឲ្យ** អង្គជំនុំជម្រះតុលាការកំពូល អនុញ្ញាតពេលវេលាបន្ថែមឲ្យ ខៀវ សំផន នៅក្រោយពេលដែលបានទទួលការបញ្ជាក់ជាលាយលក្ខណ៍អក្សរថា គាត់និងក្រុមមេធាវីការពារក្តីរបស់គាត់ នឹងមិនប្រើប្រាស់នូវការពន្យារពេលនេះដើម្បីធ្វើការបង្អាក់ដល់កិច្ចដំណើរការនីតិវិធីសវនាការលើសំណុំរឿង០០២/០២ នេះតែប៉ុណ្ណោះ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៤ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | | |

[5] **E1/246.1** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង០០២/០២, ២៤ វិច្ឆិកា ២០១៤, ត្រង់ ENG ERN 01040220។